ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០៤/១/០៧-កញ្ញា-២០០៩-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 004/1/07-09-2009-ECCC/SC

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម ម៉ុង មុនីចរិយា** |
| | **ចៅក្រម Maureen Harding CLARK** |
| | **ចៅក្រម យ៉ា ណារិន** |
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០២១** |
| **ភាសាដើម៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ:** |

---

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សារណាពាក់ព័ន្ធនៅនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤

---

| | |
|---|---|
| **<u>សហព្រះរាជអាជ្ញា</u>** | **<u>ជនជាប់ចោទ</u>** |
| ជា លាង | យឹម ទិត្យ |
| Brenda J. HOLLIS | |

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុង</u>**

**<u>សំណុំរឿង ០០៤</u>**

**<u>សហមេធាវីជនជាប់ចោទ</u>**

លោក សូ មូហ្សេន្ទី

Suzana TOMANOVIĆ

1. **អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” ឬ“អង្គជំនុំជម្រះ” និង “អ.វ.ត.ក” នីមួយៗ) បានទទួល“សំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលដាក់សារណាពាក់ព័ន្ធទៅនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤” (“សំណើសុំពន្យារពេល”)[1]។

## ក . ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ (“សេចក្តីសម្រេចរួមរបស់អង្គបុរេជំនុំជម្រះ”)[2]។

3. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជូនសំណើរបស់ខ្លួនសុំដាក់សារណាមួយភាសាជាបឋមសិន ហើយការបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ[3]។ អង្គជំនុំជម្រះបានសម្រេចបដិសេធសំណើសុំនេះនៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២១[4]។

4. នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងដំណុំរឿង ០០៤(“សេចក្តីពិចារណានៃសំណុំរឿង ០០៤”)[5]។

---

[1] សំណើសុំបន្ថែមពេលវេលា ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០២១។

[2] សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ (“សេចក្តីសម្រេចរួមរបស់អង្គបុរេជំនុំជម្រះ”) ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D271/5 & D272/3។

[3] សំណើសុំ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០២១។

[4] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់មួយភាសា ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២១។

[5] សេចក្តីពិចារណា ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D381/45 & D382/43។

5. នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជូនតាមអ៊ីម៉ែលនូវសំណើបច្ចុប្បន្នសុំការពន្យារពេលពាក់ព័ន្ធទៅនឹងសារណានៃសំណុំរឿង ០០៤[6]។ នៅថ្ងៃដដែល សហមេធាវីការពារក្តី យឹម ទិត្យ បានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលនេះ តាមរយៈអ៊ីម៉ែល និងបានលើកការជំទាស់។

## ខ. សារណា

6. សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល ដាក់សារណាក្នុងសំណុំរឿង ០០៤ នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០២១ ជាភាសាខ្មែរ និងអង់គ្លេស[7]។ សារណាដែលស្នើសុំក្នុងសំណុំរឿង ០០៤ (ដូចគ្នានឹងសារណាក្នុងសំណុំរឿង ០០៣) សុំការបំភ្លឺភាពជាក់លាក់ផ្នែកច្បាប់ ពាក់ព័ន្ធទៅនឹងការបញ្ចប់សំណុំរឿង ០០៣ នៅដំណាក់កាលមុនការជំនុំជម្រះ ជំហានបន្ទាប់នៃសំណុំរឿង និងភាពចាំបាច់ក្នុងការអនុវត្តន៍នូវសុចរិតភាពនៃក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.[8]។ គាត់បានអះអាងថា សារណារបស់គាត់ក្នុងសំណុំរឿង ០០៤ ដោះស្រាយ"បញ្ហាស្មុគស្មាញជាមូលដ្ឋាន ដែលមានលក្ខណៈចាំបាច់ចំពោះការផ្តល់យុត្តិធម៌ត្រឹមត្រូវតតលម្មៀង"[9]។ ជាលទ្ធផល ការពិនិត្យម៉តចត់លើសេចក្តីពិចារណានៃសំណុំរឿង ០០៤ មានភាពចាំបាច់ ដូច្នេះសំណើសុំពន្យារពេលរបស់គាត់ គប្បីត្រូវបានទទួលយក[10]។

## គ. ច្បាប់ជាធរមាន

7. មាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. ("សេចក្តីណែនាំអនុវត្ត") ចែងថា "លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. ឬសេចក្តីណែនាំអនុវត្ត ឬបទបញ្ជាពីអង្គជំនុំជម្រះនៃ អ.វ.ត.ក. សារណា និងពាក្យស្នើសុំ ត្រូវដាក់ទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះដែលត្រូវបានចំណាត់ការ ជាមួយនឹងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលប្រើប្រាស់ជាឯកសារយោង

[6] សំណើសុំពន្យារពេល ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០២១។

[7] សំណើសុំពន្យារពេល កថាខណ្ឌ ៨។

[8] សំណើសុំពន្យារពេល កថាខណ្ឌ ៤។

[9] សំណើសុំពន្យារពេល កថាខណ្ឌ ៥។

[10] សំណើសុំពន្យារពេល កថាខណ្ឌ ៥។

អនុលោមទៅតាមពេលវេលាកំណត់ដូចខាងក្រោម ហើយត្រូវបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន ៣៩ នៃវិធានផ្ទៃក្នុង ប្រសិនបើមានការស្នើសុំពន្យារពេលកំណត់”។

8. វិធាន ៣៩(២) នៃវិធានផ្ទៃក្នុង ចែងថា “លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង និង ស្របតាមសេចក្តីណែនាំអនុវត្ត ចៅក្រមអាចកំណត់ពេលវេលាសម្រាប់ដាក់សារណា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងឯកសារពាក់ព័ន្ធទៅនឹងសំណើសុំណាមួយ ឬបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ ដោយគិតពិចារណាដល់កាលៈទេសៈនៃរឿងក្តីនោះ ជាពិសេសក្នុងករណីដែលជនត្រូវចោទ ឬជនជាប់ចោទ ស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន”។

## ឃ. ការពិភាក្សា

9. សហព្រះរាជអាជ្ញាអន្តរជាតិបានយោងច្បាស់លាស់លើហេតុផលដូចគ្នាសម្រាប់ដាក់សារណាក្នុង សំណុំរឿង ០០៣ និង ០០៤ គឺ “សុំការបំភ្លឺ និងភាពជាក់លាក់ផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងការបញ្ចប់សំណុំរឿង នៅដំណាក់កាលមុនការជំនុំជម្រះ ជំហានបន្ទាប់ និងការអនុវត្តន៍នូវសុចរិតភាពនៃក្របខ័ណ្ឌគតិយុត្តិនៃ អ.វ .ត.ក.”[11]។ គាត់ក៏បានលើកឡើងផងដែរថា មានភាពចាំបាច់សម្រាប់ការពិនិត្យឱ្យបានម៉ត់ចត់នៃសេចក្តីពិចារណាលើសំណុំរឿង ០០៤ និង ថា សារណានៃសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងបញ្ហាស្មុគស្មាញជាមូលដ្ឋានដែលមានលក្ខណៈសំខាន់ចំពោះការផ្តល់យុត្តិធម៌ត្រឹមត្រូវ និងសមស្រប[12]។

10. អង្គជំនុំជម្រះយោងទៅលើសេចក្តីសម្រេចខ្លួនស្តីពីសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់មួយភាសា ដែលបានចេញនៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២១ និងបានបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ ដាក់សារណាជាពីរភាសា ខ្មែរ និងអង់គ្លេសក្នុងពេលតែមួយ[13]។ អង្គជំនុំជម្រះរក្សាជំហរដដែលដោយគ្មានការប្រែប្រួល។

11. អង្គជំនុំជម្រះពុំអាចពិនិត្យលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលតាមវិធាន ៣៩(២) នៃវិធានផ្ទៃក្នុងបាន រហូតទាល់តែមានការដាក់សារណាពេញលេញ និងដាក់នៅចំពោះមុខអង្គជំនុំជ

[11] សំណើសុំពន្យារពេល កថាខណ្ឌ ៤។

[12] សំណើសុំពន្យារពេល កថាខណ្ឌ ៥។

[13] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់មួយភាសា ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២១។

ម្រះ។ សហព្រះរាជអាជ្ញាអន្តរជាតិអាចតាមឆន្ទានុសិទ្ធិរបស់ខ្លួនដាក់សារណាចំពោះមុខអង្គជំនុំជម្រះជាពីរភាសាក្នុងពេលតែមួយ។

## ខ. ផ្នែកសម្រេចសេចក្តី

12. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖

**អនុញ្ញាត**សហព្រះរាជអាជ្ញាអន្តរជាតិ ដាក់សារណារបស់ខ្លួនជាភាសាខ្មែរ និងអង់គ្លេសក្នុងពេលតែមួយ។

**រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០២១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**